

ការទទួលយកមកពីព្រះជាម្ចាស់



(10)

នេះគឺជាពាក្យរបស់លោក ដេវក ព្រីនស៍
ដែលបានដកស្រង់ពីព្រះបន្ទូលនៃព្រះសម្រាប់លោកអ្នក។

> យ៉ូហានឆ្លើយថា គ្មានមនុស្សណាអាចនឹងទទួលអ្វីបានទេ
> លើកលែងតែបានប្រទានពីស្ថានសួគ៌មកឲ្យប៉ុណ្ណោះ។
> [យ៉ូហាន ៣:២៧]

ជាទូទៅមានវិធីពីរយ៉ាងក្នុងការទទួលបានរបស់។
មួយគឺការទទួលយក ហើយមួយទៀតគឺការកញ្ឆក់យក។
មានមនុស្សជាច្រើនទទួលបានរបស់ដោយការកញ្ឆក់យក
ប៉ុន្តែបញ្ហាជាមួយនឹងការកញ្ឆក់យក
គឺជាអ្វីដែលអ្នកទទួលបានមិនជាអចិន្ត្រៃយ៍នោះទេ។
អ្នកអាចមានវាក្នុងពេលមួយរយៈ
ប៉ុន្តែនៅទីបំផុតវានឹងមិនមែនជារបស់អ្នកទៀតឡើយ។
មានរបៀបមួយផ្សេងទៀតដើម្បីទទួលបានរបស់ គឺទទួលយក។
ដើម្បីទទួលយកនូវអ្វីដែលព្រះមានសម្រាប់អ្នក។

ហើយចុងបញ្ចប់អ្នកនឹងមិនមានអ្វីលើសពីអ្នកទទួលបានពីព្រះនោះទេ
។ ការតែមួយគត់ ដែលនៅជាអចិន្ត្រៃយ៍នៅក្នុងជីវិតរបស់អ្នក
ឬនៅក្នុងខ្ញុំ គឺជាអ្វីដែលយើងបានទទួលពីព្រះ។

ដូច្នេះហេតុអ្វីបានជាអ្នកមិនបញ្ឈប់ការកញ្ឆក់យកបានតែមួយភ្លែត។
ចូរឈប់កញ្ឆក់យក ចូរបញ្ឈប់ព្យាយាមកញ្ឆក់យក
ហើយគ្រាន់តែងាកបែរទៅឯព្រះ ហើយទូលថា៖ «ព្រះជាម្ចាស់អើយ
អ្វីក៏ដោយដែលទ្រង់ចង់ឱ្យខ្ញុំមាន នោះហើយជាអ្វីដែលខ្ញុំចង់បាន។
ខ្ញុំនឹងពេញចិត្ត។ ខ្ញុំនឹងមិនដេញតាមការកតំណែងធំនោះ
ឬប្រាក់ដ៏ច្រើន ឬទម្រង់នៃការសប្បាយពិសេសណាមួយនោះទេ
លុះត្រាតែព្រះអង្គប្រទានឲ្យទើបទូលបង្គំអាចទទួលបានវា»។

ដោយសារតែអ្វីដែលអ្នកទទួលពីព្រះនឹងផ្តល់ជាព្រះពរមកដល់អ្នក។
វានឹងក្លាយជារបស់អ្នកជាពិត។ វានឹងមាននៅជាអចិន្ត្រៃយ៍។
នៅទីបញ្ចប់ វានឹងមិនធ្វើឱ្យអ្នកឈឺចាប់ទេ។
របស់អ្វីដែលអ្នកទទួលបានដោយការកញ្ឆក់យក
ជាញឹកញាប់នៅទីបញ្ចប់ អ្នកនឹងសោកស្តាយ
នៅរាល់ពេលដែលអ្នកបានលូកចាប់ និងកញ្ឆក់យកពួកវា។
ដូច្នេះចូរចងចាំថា របស់ដែលមានសុវត្ថិភាព
របស់ដែលនាំមកនូវសន្តិភាព សេចក្តីសុខសាន្ត និងព្រះពរពិត
គឺជាអ្វីដែលអ្នកបានទទួលពីស្ថានសួគ៌និងទទួលបានមកពីព្រះប៉ុ
ណ្ណោះ។


«ព្រះយេស៊ូវគឺជាចំណុចស
ម្រេចជោគវាសនានៃព្រលឹងមនុស្ស។
ជីវិតអស់កល្បជានិច្ចរបស់ពួកគេ
ត្រូវបានកំណត់ដោយថាតើពួកគេនៅខាង
derekprince.com/km/resources
Cut here to use as a bookmark